ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំមាន ពិនិត្យពិភាក្សាលើការប្រមូលករណីការរើសអើង និងមាក់ងាយ ការរៀបចំផែនការសម្រាប់ធ្វើសិក្ខាសាលាបញ្ច្រាប និងរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានការឯកភាពលើការប្រមូលករណី ការរៀបចំផែនការសម្រាប់ធ្វើសិក្ខាសាលាបញ្ច្រាប និងរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ: ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍,MHC, MHSS,SIT,RHAC,CPN+, CSSD,UNAIDS,FHI360,AHF,Khemara,and MEC.

### ៣-វិធីសាស្ត្រ ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃសុក្រ ទី២៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាជិកចូលរួមប្រមាណ១៨នាក់ ក្រោម

Scanned by CamScanner

ការសម្របសម្រួលកិច្ចប្រជុំដោយ លោកផល សុផាត សមាជិកក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចចាប់ផ្តើម លោកប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការ ដែលបានចូលរួមប្រជុំនាពេលនេះ ព្រមទាំងពិនិត្យពិភាក្សាលំអិតលើរបៀបវារៈនីមួយៗដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១.ការរៀបចំផែនការសម្រាប់ធ្វើសិក្ខាសាលាបញ្ច្រាបការរើសអើង និងមាក់ងាយលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ជាមួយអ្នកផ្តល់សេវា ដោយអង្គការAHFស្នើសុំអង្គការជាដៃគូស្វែងរកអ្វីជាឧបសគ្គធ្ងន់ធ្ងរ និងដំណោះស្រាយការរើសអើង និងមាក់ងាយនៃការផ្តល់សេវាពិនិត្យសុខភាពដល់ក្រុមគោលដៅ។ ជាមួយគ្នានោះខាង UNAIDS នឹងបានចែករំលែកនូវឯកសារ(Tool Kid) ទាក់ទងនឹងការរើសអើង និងមាក់ងាយចំពោះក្រុមប្រឈមមុខខ្ពស់ និងមានការផ្តល់វគ្គបណ្តុះបណ្តាលនៅខែក្រោយ។

២.អង្គការCCHRតាមរយៈគម្រោងសូជីក្នុងការប្រមូលករណីសិក្សាស្តីពីការរំលោភបំពាន និងការរើសអើង និងមាក់ងាយលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

៣.របៀបវារៈសម្រាប់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសម្រេចដូចខាងក្រោម:

១.បទបង្ហាញពីគម្រោងសូជី ក្នុងការប្រមូលករណីសិក្សាស្តីពីការរំលោភបំពាន និងការរើសអើង និងមាក់ងាយលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញដោយ CCHR។

២.បទបង្ហាញពីផែនការសកម្មភាពសម្រាប់អនុវត្តលើក្រុមស្រីស្រស់ បន្ទាប់ពីការសិក្សាស្រាវជ្រាវថ្មីៗបង្ហាញនូវអត្រាប្រេវ៉ាឡង់ខ្ពស់(៥.៩%) និងការថយចុះនៃការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមស្រីស្រស់ បង្ហាញដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ(NCHADS)។

៣.បទបង្ហាញពីផែនការសកម្មភាព និងយន្តការនៃការអនុវត្តន៍ពីការរំលោភបំពាន និងការរើសអើង និងមាក់ងាយចំពោះក្រុមប្រឈម បង្ហាញដោយក្រសួងកិច្ចការនារី។

៤.បទបង្ហាញពីផែនការសកម្មភាព និងយន្តការនៃការផ្តល់ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្រុមប្រឈម បង្ហាញដោយក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ។

Scanned by CamScanner

៥.បទបង្ហាញ ពីរបាយការណ៍វឌ្ឍនភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញដោយក្រុមការងារលេខាធិការដ្ឋាន។

៤. ការរៀបចំកម្មវិធីផ្សេងៗក្នុងបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ និងទិវា១ធ្នូ នឹងផ្តល់ព័ត៌មាននៅពេលក្រោយ។

## ៥-សំណូមពរ និងអនុសាសន៍

១. អង្គការ Khemara ស្នើសុំផ្តល់ថវិកាដល់សមាជិក និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះសីហនុបានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

២. អង្គការ RHAC មានថវិកាខ្លះសម្រាប់ឧបត្ថម្ភដល់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

## ៦-ការងារដែលត្រូវធ្វើបន្ត

១.ក្រុមការងារលេខាធិការដ្ឋាននឹងរៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ដឹកនាំកិច្ចប្រជុំដោយអង្គការCSSD។

២.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅដើមខែធ្នូ ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។

៣.រៀបចំរបាយការណ៍របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

ភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦

បានឃើញ និងពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋាន

អ្នកធ្វើរបាយការណ៍

4-11-16